ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៥៣...០១៨...២៥៦១...ធ.ជ.ក

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨

# សេចក្ដីជូនដំណឹង
# ស្ដីពីយុទ្ធនាការស្រលាញ់ប្រាក់រៀល

ធនាគារជាតិនៃកម្ពុជាមានសេចក្ដីសោមនស្សរីករាយសូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា យុទ្ធនាការស្រលាញ់ប្រាក់រៀល នឹងត្រូវរៀបចំឡើងដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ខាងមុខនេះ ចាប់ពីថ្ងៃចន្ទ ៩រោច ដល់ថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០៩ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨ ។

យុទ្ធនាការនេះ នឹងផ្ដល់ឱកាសជូនសាធារណជនដែលមានក្រដាសប្រាក់រៀលចាស់ ទក់ ឬ រហែក អញ្ជើញមកដូរយកក្រដាសប្រាក់រៀលថ្មី នៅតាមបញ្ជរបេឡារបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្ដាល) រៀងរាល់ម៉ោងធ្វើការ ។

ក្នុងឱកាសឆ្នាំថ្មីនេះ ធនាគារជាតិនៃកម្ពុជា សូមគោរពជូនពរ សម្ដេច ឯកឧត្តម លោកជំទាវ អ្នកឧញ៉ា លោក លោកស្រីទាំងអស់ សូមជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ!

ទំនាក់ទំនងព័ត៌មានបន្ថែម
ទូរស័ព្ទ៖ ០២៣-៩៨០-១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh